

DEREK PRINCE MINISTRIES INTERNATIONAL

ផតខាស

ចូរឲ្យគំនិតរបស់លោកអ្នកបានកើតជាថ្មី



How To Find God's Plan For Your Life
ដោយ ដេរេក ព្រីនស៍

ជាព្រះពរណាស់ដែលយើងបានជួបគ្នាជាថ្មីម្តងទៀតនៅថ្ងៃនេះ ហើយថ្ងៃនេះ ខ្ញុំនឹងចែកបាយជាមួយ លោកអ្នកបចេញពីសេចក្តីពិត ដែលជីវិតបានបង្រៀនខ្ញុំ។ សេចក្តីពិតដែលបានធ្វើឲ្យមានភាពខុសគ្នា រវាងជ័យ ជម្ទះ និងបរាជ័យនៅក្នុងជីវិតរបស់ខ្ញុំ ហើយក៏អាចកើតឡើងដូចគ្នានៅក្នុងជីវិតរបស់លោកអ្នកដែរ។ ជាដំបូង ខ្ញុំសូមអរគុណលោកអ្នកដែលបានសរសេរមកខ្ញុំ។ មុននឹងបញ្ចប់ការចែកចាយនេះ យើងនឹងជម្រាបជូនលោកអ្នក អំពីអាស័យដ្ឋានទំនាក់ទំនង ដែលលោកអ្នកអាចសរសេរមកយើងខ្ញុំ។ សូមកុំស្ទាក់ស្ទើរនឹងចែកចាយប្រាប់យើងខ្ញុំ អំពីសេចក្តីត្រូវការ អំពីបញ្ហា និងអំពីសំណូមអធិស្ឋានរបស់លោកអ្នក។

សប្តាហ៍នេះ ខ្ញុំកំពុងចែកចាយជាមួយលោកអ្នកអំពីគោលដ៏សំខាន់មួយសម្រាប់យើងគ្រប់គ្នា គឺ៖ «របៀបរកឲ្យឃើញផែនការរបស់ព្រះ សម្រាប់ជីវិតលោកអ្នក»។

ក្នុងការចែកចាយពីរវគ្គខាងដើម ខ្ញុំបានពន្យល់អំពីដំណាក់កាលពីរនៃជំហានដំបូង។ ជំហានទី១គឺ: អនុញ្ញាតឲ្យព្រះ បង្កើតយើងជាថ្មីនៅក្នុងអង្គព្រះគ្រីស្ទ។ ជំហានទីពីរ: ថ្វាយរូបកាយរបស់យើងដល់ព្រះ ទុកជា យញ្ញបូជារស់។ នៅពេលដែលយើងឈានពីរជំហាននេះហើយ ព្រះទ្រង់ចាប់ផ្តើមកែគំនិតរបស់យើងជាថ្មី គឺបំ ផ្លាស់បំប្រែរបៀបដែលយើងគិត។ បន្ទាប់មក ព្រះអង្គបើកបង្ហាញមកកាន់គំនិតដែលបានកែជាថ្មីរបស់យើង) យើងស្គាល់ព្រះ ហទ័យរបស់ព្រះអង្គ តាមដំណាក់កាលបីជាបន្តបន្ទាប់:ទីមួយ ល្អ ,ទីពីរ ស្រួលទទួល និងទី៣ គ្រប់លក្ខណ៍។ និយាយបានម៉្យាងទៀតថា យើងកាន់តែស្គាល់ការបើកសម្តែងអំពីព្រះហទ័យរបស់ព្រះ ជីវិត យើងគឺកាន់តែប្រសើរឡើង។

ថ្ងៃនេះ ខ្ញុំនឹងពន្យល់ប្រាប់លោកអ្នកឲ្យកាន់តែពេញលេញថែមទៀត អំពីលក្ខណៈនៃតំនិតដែលបានកែ ជាថ្មី។ វគ្គមុន យើងបានមើលទៅអ្វីដែលលោកប៉ូលបានថ្លែងក្នុងគម្ពីររ៉ូម ១២:១,២ ហើយនៅខ ២ លោក មានប្រសាសន៍អំពីការកែជាថ្មីនៅក្នុងគំនិតរបស់យើង។ ឥឡូវនេះខ្ញុំ នឹងអានខបន្ទាប់ គឺរ៉ូម ១២:៣ ដើម្បី ពន្យល់ពីអ្វីដែលកើតឡើង នៅពេលដែលគំនិតរបស់យើងបានកែជាថ្មី:

> ដ្បិតខ្ញុំនិយាយនឹងមនុស្សទាំងអស់ក្នុងពួកអ្នករាល់គ្នា ដោយព្រះគុណដែលទ្រង់បានផ្តល់មកខ្ញុំថា ចូរគិតបែបឲ្យមានគំនិតនឹងធឹង តាមខ្នាតនៃសេចក្តីជំនឿ ដែលព្រះបានចែកមកអ្នករាល់គ្នានីមួយៗ កុំឲ្យមានគំនិតខ្ពស់លើសជាងគំនិតដែលគួរគប្បីឲ្យគិតនោះឡើយ។

នៅថ្ងៃនេះ ខ្ញុំបង់បង្ហាញលោកអ្នកអំពីសញ្ញាសម្គាល់បួននៃគំនិតដែលបានកែជាថ្មី ហើយពេលដែលខ្ញុំ ពន្យល់អំពីសញ្ញាសម្គាល់ទាំងនេះ លោកអ្នកនឹងរកឃើញថា ការនេះពិតជាជួយឲ្យលោកអ្នកចេះពិនិត្យមើល គំនិតផ្ទាល់របស់លោកអ្នក ដោយញ្ញាយាមពិនិត្យមើលតំនិតរបស់លោកអ្នក ជាតើបានកែជាថ្មីកម្រិតណា ហើយ ជា តើនៅមានផែកណាខះដែលនៅតែត្រូវការការកែជាថ្មី។

ជាដំបូង គំនិតដែលបានកែជាថ្មី គឺមិនមែនខ្លួនឯងជាសំខាន់ តែគឺជាព្រះ វិញដែលសំខាន់។ គំនិតដែល បានកែជាថ្មី លែងជម្រុញដោយកិរិយាសព្ទទាំងបីនោះ ទៀតហើយ គឺ«ខ្ញុំចង់បាន ខ្ញុំគិត ខ្ញុំមានអារម្មណ៍»។ ផ្ទុយទៅវិញ គំនិតនោះត្រូវបានជម្រុញដោយគុណតម្លៃរបស់ព្រះ គោលប៉ំណងរបស់ព្រះ គោលជៅរបស់ព្រះ។ ហើយឥឡូវនេះ ការទាំងនេះត្រឡប់ជាកាន់តែសំខាន់សម្រាប់យើង ជាង់ខ្លួនយើង

ផ្ទាល់។ ខ្ញុំសូមលើកឧទាហរណ៍ ជូនខ្លះ អំពីអ្វីដែលខ្ញុំចង់និយាយ។ នៅក្នុង ១កូរិនថូស ១០:៣១ លោកប៉ូលថ្លែងថា:

> ដូច្នេះ ទោះបើស៊ី ឬផឹក ឬធ្វើការអ្វីក៏ដោយ នោះចូរធ្វើទាំងអស់ សម្រាប់ចម្រើនសិរីល្អដល់ព្រះចុះ។

សូមកត់សម្គាល់មើលឃ្លាចុងក្រោយ «ចូរធ្វើអ្វីៗទាំងអស់សម្រាប់ជាសិរីល្អដល់ព្រះ» នេះហើយជាការជ អ្រុញនៃគំនិតដែលបានកែជាថ្មី។ សេចក្តីប៉ងប្រាថ្នា និង គោលបំណងនៃគំនិតដែលបានកែជាឬី គឺធ្វើអ្វីៗដែល ថ្វាយតិរីល្អដល់ព្រះ ពោលគឺ ធ្វើអ្វីដែលលើកតម្កើងព្រះកិត្តិនាមរបស់ព្រះ។ គំនិតនោះមិនមែនសួរថា «តើការ នេះ ដើម្បីខ្ញុំ? តើខ្ញុំនឹងបានអ្វីចេញពីការនេះ?» តែសួរជា «តើព្រះនឹងទទួលសិរីល្អ ដោយសារពីការនេះឬទេ» ហើយបន្ទាប់មក ជាថ្មីម្តងទៀតនៅក្នុងម៉ាថាយ ៦:១០ ក្នុងសេចក្តីអធិស្ឋានរបស់ព្រះអម្ចាស់ ព្រះយេស៊ូវ បង្រៀនយើងឲ្យអធិស្ឋាន ដូច្នេះថា:

> ១០ សូមឲ្យព្រះរាជ្យរបស់ព្រះអង្គបានមកដល់ សូមឲ្យ ព្រះហឫទ័យព្រះអង្គបានសម្រេច នៅផែនដី ដូចនៅស្ថានសួគ៌ ដែរ។ (RKOV)

នៅពេលយើងអធិស្ឋានដូច្នេះ នោះយើងលះចោលបំណង់ផ្ទាល់ខ្លួនរបស់យើង ហើយ។ យើងប្រកាសជា ធរមានថា «ប្រសិនបើបំណងរបស់ខ្ញុំ ទាស់ប្រឆាំងនឹង បំណងរបស់ព្រះ នោះសូមឲ្យបំណងរបស់ព្រះបានសម្រេច ចុះ កុំតាមចិត្តរបស់ខ្ញុំ ឡើយ» នោះ ហើយជាសញ្ញាសម្គាល់មួយនៃគំនិតដែលបានកែជាថ្មី។ ហើយ បន្ទាប់មក គំនិតដែលបានកែជាថ្មី រួមសហការដោយការសម្រេចចិត្តជាមួយនឹង គោលបំណងដ៏ខ្ពង់បំផុតរបស់ព្រះ សម្រាប់ ផែនដីនេះ។ តើជាអ្វី? «សូមរាជ្យរបស់ ព្រះអង្គបានមកដល់។» គំនិតដែលបានកែជាថ្មី តែងនាំឆ្ពោះទៅរកការតាំងព្រះរាជ្យ របស់ព្រះនៅលើផែនដី។ គោលបំណង់ដ៏ខ្ពស់បំផុត គឺព្រះហឫទ័យរបស់ព្រះ និង ព្រះរាជ្យរបស់ព្រះ។

សញ្ញាសម្គាល់ទីពីរនៃគំនិតដែលបានកែជាថ្មី គឺជាគំនិតដែលមិនលើកតម្កើងខ្លួន ឬ ស្វែងរកប្រយោជន៍ ផ្ទាល់ខ្លួន។ លោកប៉ុលមានប្រសាសន៍ក្នុងខដែលយើងបាន លើកឡើង នៅក្នុងគម្ពីររ៉ូម ១២:៣ ថា មិនត្រូវគិតពី ខ្លួនឯង ឲ្យខ្ពស់ លើសជាង គំនិតដែលគួរគិតនោះឡើយ។ ខ្ញុំចង់ឲ្យលោកអ្នកមើលទៅពាក្យខ្លះដែលព្រះយេស៊ូវ មានបន្ទូលទៅកាន់ពួកសិស្សរបស់ព្រះអង្គ នៅក្នុងគម្ពីរម៉ាថាយ ២០:២៥-២៨៖

> 25 តែព្រះយេស៊ូវទ្រង់ហៅអ្នកទាំងនោះមក មានព្រះបន្ទូលថា អ្នករាល់គ្នាដឹងថា ពួកចៅហ្វាយនៃសាសន៍ដទៃតែងគ្រប់គ្រង លើសាសន៍របស់ខ្លួន ហើយពួកអ្នកធំក៏មានអំណាចលើគេដែរ 26 ប៉ុន្តែ មិនត្រូវឲ្យមានដូច្នោះក្នុងពួកអ្នករាល់គ្នាឡើយ គឺអ្នក ណាក្នុងពួកអ្នករាល់គ្នាដែលចង់ធ្វើជាធំ នោះនឹងត្រូវធ្វើជាអ្នក បម្រើដល់អ្នករាល់គ្នាវិញ 27 ហើយអ្នកណាក្នុងពួកអ្នកដែល ចង់បានជាលេខ១ អ្នកនោះត្រូវធ្វើជាបាវដល់អ្នករាល់គ្នាវិញ ដែរ 28 ដូចជាកូនមនុស្សបានមក មិនមែនឲ្យគេបម្រើលោក ទេ គឺនឹងបម្រើគេវិញ ហើយនិងឲ្យជីវិតខ្លួន ទុកជាថ្លៃលោះ មនុស្សជាច្រើនផង។

នោះ ជាសញ្ញាសម្គាល់ដ៏ពិសេសមួយទៀតនៃគំនិតដែលបានកែជាថ្មី ពីមិនមែន ស្វែងរកឱកាសដើម្បីត្រួត ត្រា តែដើម្បីបម្រើវិញ។ មិនមែនស្វែងរកឱកាសដើម្បី ទទួល តែរកឱកាសដើម្បីឲ្យ ដើម្បីថ្វាយ។ គំនិតនេះគឺ ត្រាប់តាមគំរូរបស់ ព្រះយេស៊ូវ ដែលទ្រង់មិនបានយាងមកឲ្យតេបម្រើ តែយាងមកបម្រើវិញ ទាំងឲ្យ ជីវិតរបស់ ព្រះអង្គទៀតផង។ សព្វថ្ងៃនេះ នៅក្នុងវប្បធម៌ទំនើបរបស់យើង គំនិតនៃ ភាពជាអ្នកបម្រើ មិនពេញនិយមទេ។ គ្រប់គ្នាសុទ្ធតែចង់ធ្វើជាចៅហ្វាយលើ ខ្លួនឯង។ គ្រប់គ្នាសុទ្ធតែចង់បានសិទ្ធិរបស់ខ្លួន។ គ្រប់គ្នាសុទ្ធតែចង់ កាច់ចង្កូត ទៅតាមផ្លូវរបស់ខ្លួន ហើយស្វែងរកតែប្រយោជន៍ផ្ទាល់ខ្លួន។ ប៉ុន្តែ នោះ មិនមែន ជាគំនិតដែលបានកែជាថ្មីទេ។ គំនិតដែលបានកែជាថ្មី មិនដែលពោលថា «តើខ្ញុំ អាចទទួលបានអ្វីទេ?» តែជា «តើខ្ញុំអាចឲ្យអ្វី បាន?» គំនិតនេះ មិនស្វែងរកការ លើកតម្កើងខ្លួន តែជាការបន្ទាបខ្លួនវិញ។ លោក មូឌី ជាអ្នកជ្យាយជំណឹងល្អ ដ៏ល្បី ល្បាញម្នាក់: អំពីខ្លួនគាត់។ គាត់និយាយថា «កាលខ្ញុំនៅក្មេង ខ្ញុំធ្លាប់គិតថា ព្រះ មានអំណោយ របស់ព្រះអង្គរៀបទុកនៅលើច្នើរ ហើយថា អំណោយដ៏ពិសេស បំផុត គឺនៅលើច្នើរខាងលើគេបង្អស់»។ គាត់ បន្ថែមថា «ប៉ុន្តែ ខ្ញុំបានយល់ ហើយថា គំនិតនេះ ផ្ទួយទៅវិញទេ។ អំណោយដ៏ពិសេសបំផុត គឺនៅបាត ច្នើរខាង ក្រោមបង្អស់។ អ្នកមិនបាច់ឈោងឡើងទៅចាប់យកនោះ ទេ គឺដើម្បីចាប់យក អំណោយនោះបាន អ្នកត្រូវ រំកិលចុះមកវិញ»។

សញ្ញាសម្គាល់ទីបី នៃគំនិតដែលបានកែជាថ្មី គឺជាគំនិតដែលនឹងធឹង ហើយប្រាកដ ប្រជា។ លោកប៉ូល មានប្រសាសន៍ម្តងទៀតក្នុងគម្ពីររ៉ូម ១២:៣ យើងត្រូវគិត ក្នុង ភាពជាមនុស្សដែលចេះពិចារណាដឹងខុសត្រូវ ហើយគម្ពីរបកប្រែមួយជ្រុងទៀត ប្រើពាក្យ «គំនិតនឹងធឹង»។ ខ្ញុំចូលចិត្តពាក្យ «គំនិតនឹងធឹង»។ គំនិត ដែលបានកែ ជាថ្មី គឺនឹងធឹង ហើយប្រាកដប្រជា។ វាជួយជៀសវាងភាពជ្រុលនិយមទាំងពីរ ផ្នែក។ ម្ខាងគឺការស្រមើស្រមៃ និងការគិតប្រាថ្នាដោយគ្មានមូលដ្ឋានច្បាស់លាស់ ហើយម្ខាងទៀតគឺការមើលងាយតម្លៃខ្លួនឯង និងការធ្លាក់ទឹកចិត្ត។

ក្នុងចំណោមយើងដែលមានកូនវ័យជំទង់ នឹងធ្លាប់មានកូននៅវ័យជំទង់ នឹងដឹង ភ្លាមថា បញ្ហាមួយនៃគំនិត របស់យុវវ័យ គឺងាយនឹងមានគំនិតរវើរវាយ ស្រមើស្រមៃ ហើយប្រាជ្ញាចង់បាននេះចង់បាននោះ។ ពិបាកសម្រាប់យុវវ័យ ក្នុង ការនៅជាប់ក្នុងភាពប្រាកដ ប្រឈមមុខនឹងការពិតដែលជាវត្តុបំណងនៃជីវិត សូម្បី តែការពិតដែលជាវត្តបំណងអំពីបុគ្គលផ្ទាល់ខ្លួនរបស់គេក៏ដោយ។ ឥឡូវនេះ យើង យល់ហើយថា សម្រាប់ មនុស្សវ័យជំទង់ ព្រះទ្រង់ប្រទានឲ្យយើងមានព្រះគុណ ដើម្បីអត់ធ្មត់ជាមួយពួកគេ។ ប៉ុន្តែ យើងត្រូវដឹងថា នោះមិនមែនជាសញ្ញាសម្គាល់ នៃភាពពេញវ័យឡើយ។ គំនិតដែលពេញវ័យ គឺមិនរវើរវាយ មិនប៉ងប្រាថ្នាផ្តេស ផ្តាស ឥតហេតុផល សុបិន្តផ្សុង និងស្រមើស្រមៃនោះឡើយ។

លក្ខណៈទូទៅមួយទៀតនៃគំនិតក្មេងជំទង់ គឺងាយនឹងបាក់ទឹកចិត្ត ហើយជាញឹក ញាប់ ក្មេងជំទង់នោះ នឹងដកខ្លួនចេញពីគេ ឬបង្ខាំងខ្លួនមិនចង់ជួបគេឯង អង្គុយ ក្លុងបន្ទប់ម្នាក់ឯង ហើយឲ្យតម្លៃខ្លួនឯងទាបទៅៗ ក្នុងនាមជាមនុស្ស។ ហើយជា រឿយៗ វាក៏បណ្តាលឱ្យមានអារម្មណ៍ប្រែប្រួលមិនទៀងទាត់ និងការធ្លាក់ទឹកចិត្ត ផងដែរ។ ជាថ្មីម្តងទៀត ស្ថានភាពទាំងនេះមិនស្របតាមគំនិតដែលបានកែប្រែថ្មី ឡើងវិញដោយព្រះបន្ទូលរបស់ព្រះឡើយ។

អស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំបានជួបប្រទះ ជាមួយនឹងបញ្ហាធ្លាក់ទឹកចិត្ត ក្នុងជីវិត របស់ខ្ញុំផ្ទាល់ ហើយទី បំផុត ក្នុងចំណោមការឯទៀតៗ ព្រះទ្រង់បានបង្ហាញខ្ញុំថា ខ្ញុំ មានការទទួលខុសត្រូវលើគំនិតរបស់ខ្ញុំផ្ទាល់។ ខ្ញុំ មិនត្រូវបណ្តោយឲ្យមានគំនិត អវិជ្ជមានទេ។ ព្រោះ ខ្ញុំត្រូវតែអប់រំគំនិតផ្ទាល់របស់ខ្ញុំឡើងវិញ ហើយត្រូវតែផ្លាស់ប្រែ នូវគំរូជាច្រើននៃការគិតរបស់ខ្ញុំ។ ពេលដែលខ្ញុំបានធ្វើដូច្នេះ ខ្ញុំក៏បានចេញរួចពី បញ្ហាដ៏ អាក្រក់នៃការធ្លាក់ទឹកចិត្តនោះ។ ដូច្នេះ នោះហើយជាសញ្ញាសម្គាល់ទីបី នៃ គំនិតដែលបានកែជាថ្មីគឺ: គំនិតនឹងធឹង ប្រាកដប្រជា។

សញ្ញាសម្គាល់ទីបួននៃគំនិតដែលបានកែជាថ្មី គឺជាអ្វីដែលមិនមែនងាយស្រួល ជានិច្ចសម្រាប់ឲ្យយើងយល់ នោះទេ។ សូមយើងត្រឡប់ទៅមើលសេចក្តីរបស់ លោកប៉ូលបានថ្លែងនៅក្នុងគម្ពីររ៉ូម ១២:៣។ លោកមាន ប្រសាសន៍ថា យើងត្រូវតែ «ចូរគិតបែបឲ្យមានគំនិតនឹងធឹង តាមខ្នាតនៃសេចក្តីជំនឿ ដែលព្រះបានចែកមក

អ្នករាល់គ្នានីមួយៗ»។ គំនិតដែល បានកែជាថ្មី គឺស្ថិតនៅក្នុងរង្វង់ ឬខ្នាតនៃជំនឿ ដែលព្រះប្រទានឲ្យ។ គំនិតនេះ មិនអួតអាង ឬការប្រកាសភាព មិនពិតប្រាកដនោះឡើយ។ គំនិតនេះ មិនប្រកាសថា មានជំនឿ ដែលមិនពិតនោះឡើយ។

បញ្ហាមួយដ៏ធំ ដែលខ្ញុំបានជួបប្រទះ ជាមួយមនុស្ស ក្នុងនាមខ្ញុំជាអ្នកបម្រើព័ន្ធកិច្ច គឺជា គេគិតថា គេមានជំនឿ លើសពីជំនឿដែលគេមាន។ គេនិយាយថា «ខ្ញុំជឿថា ព្រះនឹងធ្វើការនេះ ឬការនោះ» ហើយការនោះមិនកើត ឡើងទេ រួចមក គេក៏អស់សង្ឃឹម ហើយធ្លាក់ទឹកចិត្ត ជួនកាល គេសឹងតែនឹងបន្ទោសព្រះទៀតផង។ បញ្ហានោះ គឺថា គេទៅហួសខ្នាតនៃជំនឿដែលព្រះបានប្រទានឲ្យ។

ខ្ញុំនឹងបង្ហាញជូនលោកអ្នកនៅរគុបន្ទាប់ថា មានមូលហេតុមួយដែលព្រះទ្រង់ប្រទានខ្នាតមួយនៃជំនឿ មកយើង។ ប្រសិនសិនបើយើងយល់ពីហេតុផលរបស់ព្រះ ហើយយើងដើរស្របជាមួយនឹងព្រះ ហឫទ័យរបស់ ព្រះអង្គ យើងនឹងរកឃើញថា ខ្នាតនៃជំនឿដែលព្រះបានប្រទានមកយើង គឺពិតជាអ្វីដែលយើងត្រូវការមែន។ យើងមិនត្រូវការជំនឿលើសពីជំនឿដែលព្រះទ្រង់ចែកឲ្យយើងឡើយ។ តាមខ្នាត នៃជំនឿដែលយើងត្រូវការ ប៉ុន្តែនេះជាការកើតឡើងច្រើនបំផុតជាមួយនឹងមនុស្សបែបសាសនា ជាមនុស្សធ្វើខ្លួន ឲ្យរវើរវាយថាជារឿងវិញ្ញាណ ដើម្បីព្យាយាម និងជឿលើសពីអ្វីដែលពួកគេអាចជឿបានពិតប្រាកដ។ គំនិត នេះ នាំឲ្យមានបញ្ហាជាច្រើន។ ជួនកាល មនុស្សដែលគួរតែមានជំនួយពីគ្រូពេទ្យ តែគេរស់នៅដោយមិនខ្វល់ ព្រោះគេជឿថា គេមានជំនឿសម្រាប់ការប្រោសឲ្យជា ប៉ុន្តែគេមិនបានទទួលការប្រោសឲ្យជាឡើយ។ លោកអ្នក ឃើញទេ ជំនឿតែងបន្ទាបខ្លួនជានិច្ច។ នោះជាអ្វីដែលយើងត្រូវចង់ចាំ។ គម្ពីរហាបាគុក ២:៤ អំពីការរាប់ជាសុចរិតដោយសារជំនឿ បែងដូច្នេះថា៖

> មនុស្សព្រហើនកោងកាចមុខជាត្រូវវិនាស រីឯមនុស្សសុចរិតនឹងរស់នៅដោយសារជំនឿ។

ហេីយគម្ពីរបកប្រែចាស់ដាកថា

> ៤ មើល៍! ចិត្តគេបានប៉ោងឡើង មិនទៀងត្រង់នៅក្នុងខ្លួនគេទេ តែមនុស្សសុបរិតនឹងរស់នៅ ដោយសារជំនឿរបស់ខ្លួន។

ទោះជាយើងប្រើសំណៅបកប្រែណាមួយក៏ដោយ ក៏លោកអ្នកឃើញហើយថា មនុស្សដែលលើកតម្កើងខ្លួន នោះហើយជាមនុស្សអួតបំប៉ោង គេប្រកាសពីការដែលមិនបានរាប់ជាសុចរិត មិនមែនដោយជំនឿ។ បន្ទាបខ្លួន។ ជំនឿ គឺមិនមែន «អាត្មាអញ» ធំ ហើយ «ព្រះ» ទ្រង់តូចនោះឡើយ។ ជំនឿគឺ «ព្រះ» ទ្រង់ធំ ហើយ «អាត្មាអញ» តូច ហើយយើងត្រូវតែរស់នៅទៅតាមខ្នាតនៃជំនឿ ដែលព្រះបានប្រទានឲ្យនោះ។

យើងចូលដល់ពេលបញ្ចប់ហើយសម្រាប់ថ្ងៃនេះ ប៉ុន្តែខ្ញុំនឹងវិលមកជួបលោកអ្នកជាថ្មីទៀតនៅវគ្គក្រោយ ហើយវគ្គក្រោយ.ខ្ញុំនឹងពន្យល់ពីជំហានបន្ទាប់ក្នុងការស្វែងរកផែនការរបស់ព្រះ ដែលនឹងក្លាយជាអវៈយវៈមួយ នៅក្នុងរូបកាយដែលបំពេញតាមតួនាទី។

ផតខាស
ប្រតិចារិក: RP-R014-103-KHM
បច្ចុប្បន្នភាពចុងក្រោយ: 09 Nov 2026
គេហទំព័រ: Derekprince.com/km/resources

